**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ.....០១...សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកិច្ចសន្យាស្តីពីការជួសជុលពហុកីឡាដ្ឋានជាតិអូឡាំពិក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតលេខ ១៧៤៧ សជណ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញលិខិតលេខ ១៨៨៧ សជណ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យ និងដោះស្រាយភាពមិនប្រក្រតី និងបញ្ហាពាក់ព័ន្ធនឹងកិច្ចសន្យាស្តីពីការជួសជុលពហុកីឡាដ្ឋានជាតិអូឡាំពិក ដែលមានសមាសភាពដូចខាងក្រោម:

| | | | | | |
|---|---|---|---|---|---|
| ១. | ឯកឧត្តម | **អ៊ឹម** | **សិទ្ធី** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | ប្រធាន |
| ២. | ឯកឧត្តម | **គង់** | **វិបុល** | រដ្ឋលេខាធិការទី ១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. | ឯកឧត្តម | **សុខ** | **ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |

www.pheakdeylaw.com

| | | | | |
|---|---|---|---|---|
| ៤. ឯកឧត្តម | ហ៊ី | សោភា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៥. ឯកឧត្តម | ម៉ម | សុផាណារ | អនុរដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦. ឯកឧត្តម | សម | សុផល | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៧. ឯកឧត្តម | សួន | សិទ្ធី | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨. ឯកឧត្តម | ហ៊ឹង | ថូរ៉ាក់ស៊ី | នាយកខុទ្ទកាល័យ-ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី | សមាជិក |
| ៩. ឯកឧត្តម | ផូច | សំភី | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ១០. ឯកឧត្តម | ជា | អឿង | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១. លោក | អ៊ុន | ចាំល់ឡើ | ប្រធាននាយកដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១២. លោក | សួន | រិនឌី | នាយករងខុទ្ទកាល័យ សាលាក្រុងភ្នំពេញ | សមាជិក |

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម:

១. ពិនិត្យសុពលភាពនៃកិច្ចសន្យាស្តីពីការជួសជុល និងស្តារឡើងវិញពហុកីឡាដ្ឋានជាតិអូឡាំពិក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០០ ព្រមទាំងសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យានេះ

២. សិក្សាស្រាវជ្រាវ និងលើកយោបល់ជូនរាជរដ្ឋាភិបាលអំពីនីតិវិធីនៃច្បាប់ដ៏សមស្រប ដើម្បីលុបកិច្ចសន្យានេះចោល

៣. ដោះស្រាយបញ្ហាពាក់ព័ន្ធមួយចំនួន ដូចជាទីតាំងសាងសង់រួច ទីតាំងកំពុងសាងសង់ និងបញ្ហាផ្សេង១ទៀត ដែលពាក់ព័ន្ធទៅនឹងកិច្ចសន្យាខាងលើ ។

**ប្រការ ៣** : គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងាររបស់ខ្លួន ។

**ប្រការ ៤** : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សាលាក្រុងភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៧

**ហ៊ុន សែន**

ចំលងជូន :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ ៥

-ក្រុមហ៊ុន យាន តាយ សំណង់វិស្វកម្ម

-ឯកសា-កាលប្បវត្តិ

www.pheakdeylaw.com